# កិច្ចប្រជុំបូកសរុបលទ្ធផលការងារ និងលើកទិសដៅអនុវត្តបន្ត របស់ក្រុមការងារថ្នាក់ខេត្ត ចុះមូលដ្ឋាន ក្រុង ស្រុក ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា



កាលពីថ្ងៃទី១១ ខែ សីហា ឆ្នាំ២០១៤ ឯកឧត្តម ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងជាប្រធានក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា បានអញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារ និងលើកទិសដៅអនុវត្តបន្ត របស់ក្រុមការងារថ្នាក់ខេត្ត ចុះមូលដ្ឋាន ក្រុង ស្រុក ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា នៅសាលប្រជុំសាលាខេត្តកំពត ។




ជាកិច្ចចាប់ផ្តើម ឯកឧត្តម **ខួយ ឃុនហួរ** អភិបាលនៃគណៈអភិបាលខេត្តកំពត និងជាអនុប្រធានអចិន្ត្រៃយ៍ក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជាបានអញ្ជើញមានប្រសាសន៍ស្វាគមន៍ និងរាយការណ៍អំពីលទ្ធផលការងារកន្លងមកដោយបានបញ្ជាក់ថា: ដោយអនុវត្តតាមកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំនាក់កាលទី៣ របស់រាជរដ្ឋាភិបាលដែលមាន **សម្តេចអគ្គមហាសេនាបតីតេជោ** ហ៊ុន សែន ជាប្រមុខ សភាពការណ៍សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈនៅទូទាំងខេត្ត ទាំងភូមិសាស្ត្រក្នុងខេត្ត ក៏ដូចជាតាមព្រំដែនគោក និងព្រំដែនទឹក មានលក្ខណៈល្អប្រសើរ ដោយបទល្មើសគ្រប់ប្រភេទមានការថយចុះ បើប្រៀបធៀបរយៈពេលដូចគ្នា ក្នុងឆមាសនៃឆ្នាំកន្លងទៅ ។ នេះបង្ហាញឱ្យឃើញអំពីលទ្ធផលជាវិជ្ជមាននៃការចាត់តាំងអនុវត្តគោលនយោបាយ ភូមិ ឃុំ មានសុវត្ថិភាព របស់ខេត្ត ពីគ្រប់បណ្តាសមត្ថកិច្ចពាក់ព័ន្ធ និងអជ្ញាធរដែនដីគ្រប់ថ្នាក់ ។

ឯកឧត្តម អភិបាលខេត្ត បានបន្តថា: គិតមកទល់ពេលនេះ មានរយៈពេល១ ឆ្នាំគត់ នៃការអនុវត្តការងាររបស់រាជរដ្ឋាភិបាលកម្ពុជាអណត្តិទី៥ ។ ជាមួយគ្នានេះ ក៏មានរយៈពេល០៦ខែ ហើយដែរ នៃការអនុវត្តភារកិច្ចរបស់ក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា ។ សម្រាប់ខេត្តកំពត រដ្ឋបាលគ្រប់ថ្នាក់ និងជំនាញពាក់ព័ន្ធទាំងអស់ បានខិតខំប្រឹងប្រែងអនុវត្តការងាររបស់ខ្លួនយ៉ាងសកម្ម និងទទួលបានជោគជ័យជាបន្តបន្ទាប់គួរឱ្យមោទនៈ ក្រោមការដឹកនាំរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ ដែលស្តែងចេញនូវលទ្ធផលជាច្រើនមានដូចជា:ការបង្កើតក្រុមការងារថ្នាក់ជាតិចុះជួយស្រុកក្រុង ការបង្កើតវេទិការសាធារណៈរួមនៅឃុំថ្មី ការចុះដោះស្រាយពាក្យបណ្តឹង និងសំណូមពររបស់ប្រជាពលរដ្ឋលើកឡើងពេលមានកម្មវិធីវេទិការសាធារណៈ ជាអាទិ៍មកដល់ពេលនេះ ខេត្តដកស្រង់បាននូវប្រភេទព័ត៌មានមួយចំនួនដែលកើតមាននៅមូលដ្ឋាន ដូចជា:

**១-ការងារដឹកនាំរដ្ឋបាល និងការផ្តល់សេវាៈ** -អំពើពុករលួយ ស៊ីសំណូក និងបក្សពួក ក្នុងការអនុវត្តការងារនៅរដ្ឋបាល ថ្នាក់ក្រោមជាតិ និងមន្ទីរអង្គភាពរដ្ឋក្នុងខេត្ត-ការយកកម្រៃសេវារដ្ឋបាលលើសពីតម្លៃ ដែលរដ្ឋបានកំណត់-ការតែងតាំង មន្ត្រីតាមលក្ខណៈសម្បត្តិ-មិនយកចិត្តទុកដាក់ ក្នុងការបំពេញតួនាទី និងម៉ោងពេលបំពេញការងារជូនរដ្ឋ និងការងារបៀវត្សន៍ទាប ។

**២-ការងារសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ការបង្រ្កាបបទល្មើសនានា និងតុលាការ :** -ការផាកពិន័យតាមច្បាប់ចរាចរត៊ីងង៉ីរ៉ុងពេក រឺធូររលុងពេក-ការផាកពិន័យលើសចំនួនកំណត់-ការផាកពិន័យមិនស្មើភាព-ការឃុបឃិតជាមួយជនល្មើស(មានលុយរួចខ្លួន ចាប់លែង ចាប់លែង)-អ្នកក្រចាប់ដាក់គុក បក្សពួកអ្នកធំ អ្នកមានរួចខ្លួន-សមត្ថកិច្ច និងអាជ្ញាធរមូលដ្ឋានឃុបឃិតជាមួយជនល្មើស) ។

**៣-ការងារគ្រប់គ្រងព្រៃឈើ ដីធ្លី បរិស្ថាន និងធនធានធម្មជាតិ នេសាទ និងបទល្មើសៈ** -អាជ្ញាធរមូលដ្ឋាននិងជំនាញ មួយចំនួនឃុបឃិតលក់ដីព្រៃឱ្យឈ្មួញ-ក្រុមហ៊ុន និងអង្គភាពប្រដាប់អាវុធមួយចំនួន រំលោភយកដីរដ្ឋ (ភ្នំបូកគោ-ត្រពាំងភ្លាំង-តាកែន-ត្រពាំងរាំង-ច្រេស-ស្រែចែង)-ការឃុបឃិតឱ្យឈ្មួញ និងប្រជាជនអនាធិបតេយ្យចូល កាប់បំផ្លាញព្រៃឈើ និងដឹកជញ្ជូនឈើ(ព្រៃឈើហោចទៅៗ)-ការយកលុយរទេះដឹកឈើ(ជំនាញ និងកងកំលាំង)-ការជួញឈើមានតម្លៃទៅបរទេស-ការធ្វេសប្រហែសឱ្យទូកនេសាទបរទេស(វៀតណាម ថៃ) ចូលនេសាទ ក្នុងដែននេសាទខ្មែរ-ការរំលោភយកដីព្រៃលិចទឹក (សមុទ្រ) និងការចាក់ដីរំលោភចូលឆ្នេរសមុទ្រ-មិនសូវដែលចាប់បានពួកប្រព្រឹត្តិបទល្មើស ។

**៤-ការងារទីផ្សារ ភាស៊ី អនាម័យ សោភ័ណ្ឌភាពសាធារណៈ :** -ការបោះសម្រាមពាសវាលពាសកាលគ្មានសណ្តាប់ធ្នាប់-ការផាកពិន័យធូររលុងលើអ្នកបោះចោលសម្រាម-ការលែងសត្វពាហនៈក្នុងក្រុងពាសវាលពាសកាល-ផ្លូវហុយដី និងសម្បូរណ៍សម្រាម-ការប្រមូលសម្រាមយឺតតែថ្លៃសម្រាមខ្ពស់-ការកសាងទីក្រុង និងទីប្រជុំជនមិនទាន់បានស្រស់ស្អាត-យកថ្លៃភាស៊ីលើសសៀវភៅបន្ទុក-អ្នកយកភាស៊ីមានអាកប្បកិរិយាមិនល្អ -ផ្សារគ្មានការអភិវឌ្ឍន៍ រឺមិនព្រមអភិវឌ្ឍន៍-ផ្សារគ្មានសណ្តាប់ធ្នាប់ ស្អុយ ក្រខ្វក់(គ្មានលូបង្ហូរទឹក)-ការចតយានយន្តអនាធិបតេយ្យ (គ្មានចំណត) ។

**៥-កម្រៃសេវាទឹក ភ្លើងៈ** -ចង់បានបណ្តាញទឹកភ្លើងរបស់រដ្ឋ មានដល់គ្រប់ផ្ទះ(ពិសេសតាមទីក្រុង ទីជ្រុំជន និងតាមផ្លូវជាតិ)-សុំឱ្យសេវាទឹក ភ្លើង ទាប និងចុះតម្លៃជាងពីមុន-កុងទ័រទឹកភ្លើង ដើរលឿន-ការតបណ្តាញចូលផ្ទះថ្លៃពេក ។

**៦-កុងត្រូលដង់ដុះៈ** -សមត្ថកិច្ច និងជំនាញ ស្ទាក់យកលុយតាមផ្លូវ-បង់តិចមិនព្រមយក-ដេញស្ទាក់ចាប់មិនយោគយល់-យកច្រើនកន្លែងពេក ។

**៧-ល្បែងស៊ីសងនានា :** -មានលេងល្បែងច្រើន(ពិសេសតាមជនបទ) ជាប្រភពនៃអំពើហឹង្សា និងចោរកម្ម-មិនសូវមានការបង្រ្កាប(ពិសេសតាមជនបទ)-សមត្ថកិច្ចយកលុយ និងឃុបឃិតជាមួយមេល្បែង (កន្ទុយលេខ)-ឱ្យលុយមិនចាប់ មិនឱ្យលុយចាប់-ចាប់ហើយឱ្យលុយលែងវិញ-ផាកពិន័យអ្នកលេងល្បែងយកលុយច្រើនហួសហេតុពេក ។

**៨-អំពើហឹង្សាក្នុងគ្រួសារ ការសេពគ្រឿងស្រវឹង គ្រឿងញៀនៈ** -ឱ្យលុយមិនចាប់ មិនឱ្យលុយចាប់-ចាប់ហើយឱ្យលុយលែងវិញ ។

**០៩–ក្មេងទំនើង :** –ច្រើនជាកូនចៅអ្នកធំ និងអ្នកមាន

**១០–កង្វះហេដ្ឋារចនាសម្ព័ន្ធនានា នៅមូលដ្ឋាន:** –បន្ទប់រៀន សេវាសុខភាព (ជនបទ ដាច់ស្រយាល) –គ្មានទឹកស្អាតប្រើប្រាស់ (អណ្តូង ស្រះ) –ខ្វះផ្លូវល្អសម្រាប់ធ្វើដំណើរ–ខ្វះប្រព័ន្ធធារាសាស្ត្រ (ទំនប់ ប្រឡាយ អូរ ម៉ាស៊ីនបូមទឹក) –ខ្វះអគ្គិសនីរដ្ឋ រឺឯកជនប្រើប្រាស់ ។

**១១–អាកប្បកិរិយា និងសីលធម៌ សុជីវធម៌ របស់មន្ត្រីរាជការ មន្ត្រីមូលដ្ឋាន កងកំលាំងនានា:** –ប្រើប្រាស់ពាក្យសំដី កាយវិការមិនសមរម្យជាមួយប្រជាពលរដ្ឋ (នៅមូលដ្ឋាន និងនៅពេលទទួលសេវា) –រើសអើង និងមិនយកចិត្តទុកដាក់ចំពោះអ្នកក្រ និងជនងាយរងគ្រោះ –គម្រាមកំហែង និងប្រមាថអ្នកតូចតាចទន់ខ្សោយ ។

**១២–ការអនុវត្តការងារនៅថ្នាក់ឃុំ សង្កាត់ ស្មៀន មេឃុំ និងមន្ត្រីភូមិ:** –គិបកេងថវិកា ឃុំ សង្កាត់ –ធ្វើការតែស្មៀននិងមេឃុំ (មិនចែកការងារឱ្យគេធ្វើ) –យកលុយកម្រៃសេវាលើស (ការបញ្ជាក់លិខិតស្នាមនានា រឺអត្រានុកុលដ្ឋាន ) –បំពេញសេវាការងាររដ្ឋបាលឱ្យប្រជាពលរដ្ឋយឺតយាវ (ពេលឱ្យលុយក្រៅលឿន) –បើកប្រាក់ឧបត្ថម្ភឱ្យមន្ត្រីឃុំ សង្កាត់ និងភូមិយឺត រឺជំពាក់មិនសង –មិនឱ្យមន្ត្រីឃុំសង្កាត់ ភូមិ រឺប្រជាពលរដ្ឋដឹងពីថវិកាចំណូលចំណាយនានា ក្នុងឃុំសង្កាត់ –មានចារិកវាយឫក និងរើសអើងដាក់ប្រជាពលរដ្ឋ ពិសេសអ្នកក្រីក្រ និងអ្នកមាននយោបាយផ្សេង។

**១៣–ការផ្តល់សេវាសង្គមកិច្ច សុខាភិបាល អប់រំ និងជនក្រីក្រ:** –គ្មានប្រាក់ឧបត្ថម្ភដល់ជនក្រីក្រ ស្ត្រីមេម៉ាយចាស់ជរា និងជនងាយរងគ្រោះ ជនអនាថា –ពេទ្យ ឃើញអ្នកក្រមិនសូវយកចិត្តទុកដាក់ទទួលព្យាបាល –ពេទ្យ រដ្ឋយកថ្លៃព្យាបាលជំងឺថ្លៃ –គ្រូមិនយកចិត្តទុកដាក់ការបង្រៀន (រៀនគួច្រើន យកលុយពីសិស្ស លក់ឯកសារថ្លៃ) –សាលានៅជនបទដាច់ស្រយាល រៀនមិនទៀងទាត់ គ្មានគ្រូ ។

**១៤–ការផ្តល់បច្ចេកទេសកសិកម្ម អាជីវកម្ម ពាណិជ្ជកម្ម សេដ្ឋកិច្ច និងទំនិញ:** –ចង់ឱ្យរដ្ឋផ្តល់ការធានាលើការខ្វះខាតពូជស្រូវ ដំណាំនានា និងការព្យាបាល –សុំឱ្យរដ្ឋរកទីផ្សារលក់ផលិតផលរបស់ខ្លួនឱ្យបានអស់ និងបានថ្លៃ –សុំឱ្យទំនិញចុះថោក និងទិញបានច្រើនជាងមុន ក្នុងតម្លៃដដែល –សុំឱ្យប្រេងសាំងចុះថោក –សុំកុំឱ្យទំនិញបរទេសចូលស្រុក ពិសេសកសិផល បន្លែ ផ្លែឈើ និងសាច់សត្វ –សុំតម្លើងប្រាក់ខែ (មន្ត្រីរាជការ កម្មករ កងកំលាំងប្រដាប់អាវុធ) –សុំយកពន្ធទំនិញលក់ក្នុងស្រុកទាប –ពន្ធដារយកពន្ធទំនិញលក់ដូរច្រើនផ្នែក (សមត្ថកិច្ចច្រើន) ហើយខ្ពស់ៗទៀត –ខ្ចីលុយធនាគារ យកការប្រាក់ខ្ពស់ និងគាបសង្កត់ប្រជាពលរដ្ឋក្រីក្រ (រឹបអូសទ្រព្យសម្បត្តិ) –គយបើមិនឱ្យលុយក្រៅចាប់ទំនិញ រឺបង្អាក់ទំនិញដឹកចេញយឺតពេល –ចំណីអាហារសម្បូរណ៍ជាតិពុល និងខ្វះការត្រួតពិនិត្យ –ចំណីអាហារគ្មានគុណភាព ប្រើជាតិគីមីច្រើន –មានរត់ពន្ធប្រេង និងលក់សាំងគេចពន្ធ ។

**១៥–ការអភិវឌ្ឍន៍ក្នុងមូលដ្ឋានដែលពួកគាត់កំពុងរស់នៅ:** –មិនឃើញអ្វីរីកចម្រើនឱ្យដុំកំភួន (មានម៉េច នៅដដែល) –ចង់ឱ្យមានការអភិវឌ្ឍន៍ រីកចម្រើនឆាប់ដូចស្រុកគេ –មន្ត្រីខ្វះគ្មានគំនិតអភិវឌ្ឍន៍ –ខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ និងភូមិគ្មានថវិការគ្រប់គ្រាន់ ក្នុងការអភិវឌ្ឍន៍ ។

ឯកឧត្តម អភិបាលខេត្តបាន បញ្ជាក់បន្ថែមថាៈ ទោះបីជួបប្រទះនូវបញ្ហាប្រឈម និងសំណូមពរជាច្រើនដូចនេះក្តី ក៏ខេត្តបានដាក់ចេញនូវកិច្ចការចំពោះមុខ និងចាំបាច់របស់ខ្លួន ដើម្បីធនាធាបាននូវយន្តការដោះស្រាយ រួមមានបង្កើន ការដោះស្រាយ រាល់បញ្ហាព័ត៌មាន និងតម្រូវការរបស់ប្រជាពលរដ្ឋ ដែលបានលើកឡើងទាំងមុនពេល និងក្រោយពេលធ្វើវេទិកាសាធារណៈ ពង្រឹងការអនុវត្តច្បាប់ ការកាត់បន្ថយបទល្មើសគ្រប់ប្រភេទ និងការថ្នាំងថ្នាក់នានា ពីប្រជាពលរដ្ឋនៅមូលដ្ឋាន បន្តការអនុវត្តគោលនយោបាយ ភូមិ ឃុំមានសុវត្ថិភាព និងការអភិវឌ្ឍន៍នៅមូលដ្ឋាន ឱ្យកាន់តែខ្លាំងក្លាថែមទៀត ដូចជា ការប្រគល់ភារកិច្ចជូន ប្រធានក្រុមការងារចុះជួយស្រុក ក្រុង ធ្វើការចុះប្រជុំដឹកនាំក្រុមការងារ ស្រុក ក្រុង នៅតាមមូលដ្ឋានរបស់ខ្លួនជាបន្តបន្ទាប់ ។




បន្ទាប់ពី អានប្រកាសស្តីពីការតែងតាំង ប្រធាន-អនុប្រធាន និងសមាជិក នៃក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ក្រុង០១ ស្រុក ០៧ នៅទូទាំង ខេត្តកំពត រួចមក ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានអញ្ជើញមានប្រសាសន៍ សម្តែងនូវការកោតសរសើរដល់ អជ្ញាធរខេត្ត និងក្រុមការងារ ដែលបានខិតខំអភិវឌ្ឍន៍មូលដ្ឋានតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ។ ជាមួយគ្នានេះបាន រៀបចំចងក្រងឯកសារយ៉ាងល្អប្រសើរសម្រាប់ក្រុមការងារត្រៀមអនុវត្តភារកិច្ចរបស់ខ្លួន ប្រកបដោយការទទួលខុសត្រូវខ្ពស់ ។ ឯកឧត្តម ទេសរដ្ឋមន្ត្រី បានបញ្ជាក់ថាៈកម្រងបញ្ហាទាំងអស់ខាងលើ មិនមែនសុទ្ធតែជាបញ្ហាសចោតម្រាប់គ្រប់អាជ្ញាធរមូលដ្ឋានពាក់ព័ន្ធទាំងអស់ទេ តែអាចមានពាក់ព័ន្ធបញ្ហាមួយចំនួនណានោះ រឺមួយចំនួនណានោះមូលដ្ឋានផ្សេងៗក៏បានដោះស្រាយបានជាច្រើនផងដែរ ។ ទោះជាយ៉ាណា ឯកឧត្តម ទេសរដ្ឋមន្ត្រី បានស្នើឱ្យសមាជិកក្រុមការងារទាំងអស់ពិចារណា ស្វែងរកដំណោះស្រាយ នូវបញ្ហាដែលមានពាក់ព័ន្ធនិងមូលដ្ឋានរបស់ខ្លួន ហើយបញ្ហាដែលមិនទាន់ដោះស្រាយបានត្រូវមានហេតុផល ច្បាស់លាស់ ហើយត្រូវស្វែងយល់ និងយកច្បាប់មាត្រា សារាចរណែនាំនានា ជាអំណះអំណាង សម្រាប់ផ្តល់ជូនប្រជាពលរដ្ឋពិចារណា ស្វែងយល់ និងមានភាពស្ងប់ចិត្ត ។ ចំណែកឯបញ្ហា ដែលមិនអាចដោះស្រាយបាននៅថ្នាក់មូលដ្ឋានរបស់ខ្លួន ត្រូវធ្វើរបាយការណ៍ទៅថ្នាក់លើដោះស្រាយបន្ត មិនត្រូវទុកចោលមិនចាត់ការឡើយ ។

ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានស្នើឱ្យក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានក្រុង ស្រុក ដែលទើបតែងតាំងរួច រៀបចំក្រុមការងារថ្នាក់ឃុំ ស្រុក បន្តទៀត ដើម្បីពន្លឿនការធ្វើវេទិកាសាធារណៈឱ្យបា នគ្រប់ទាំង៨៨ ឃុំ–សង្កាត់ នៅចុងខែនេះ ។ បន្ទាប់មកយើងនឹងអាចដាក់របាយការណ៍ជូនរាជរដ្ឋាភិបាល នៅដើមខែកញ្ញា ដើម្បីជាមូលដ្ឋានសម្រាប់ការប្រជុំបូកសរុបលទ្ធផលការងាររយៈពេល០១ ឆ្នាំ នៃរាជរដ្ឋាភិបាលកម្ពុជាអណត្តិទី៥ កំឡុងខែកញ្ញា ខាងមុខនេះ។









ឆ្លៀតឱកាសនោះ ឯកឧត្តម ទេសរដ្ឋមន្រ្តី ចម ប្រសិទ្ធ ក៏បានស្នើឱ្យអាជ្ញាធរខេត្ត ក៏ដូចជា អង្គភាព-មន្ទីរ ពាក់ព័ន្ធ ដែលមានប្រជាពលរដ្ឋ មន្រ្តីរាជការ រឺកងកំលាំងប្រដាប់អាវុធ រស់នៅមន្ទីរ-អង្គភាពរបស់ខ្លួន ជាយូរមកហើយ គួរស្វែងរកដំណោះស្រាយសមស្រប ជៀសវាងទុកអូសបន្លាយជាយូរអង្វែងទៅមុខទៀត ។